00209647

A162/III/5


អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គបុរេជំនុំជម្រះ
PRE-TRIAL CHAMBER
CHAMBRE PRELIMINAIRE


សំណុំរឿងព្រហ្មទណ្ឌ លេខ: ០០២/១៩-០៩-២០០៧-អវតក-កសចស (អបជ០៨)

ចំពោះមុខ:
ចៅក្រម ប្រាក់ គីមសាន ប្រធាន
ចៅក្រម Rowan DOWNING
ចៅក្រម នុ័យ ថុល
ចៅក្រម Katinka LAHUIS
ចៅក្រម ហួត វុទ្ធី

កាលបរិច្ឆេទ: ០៤ សីហា ២០០៨

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 04 / AUG / 2008
ម៉ោង (Time/Heure): 15:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: C.A. FRY

---

## សេចក្តីសម្រេចលើសំណើសុំសេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី ដោយផ្អែកលើសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរតែប៉ុណ្ណោះ

---

**ការិយាល័យសហព្រះរាជអាជ្ញា**
ជា លាង
Robert PETIT
យ៉េត ចរិយា
William SMITH
តាន់ សេណារ៉ុង
Anees AHMED

**ជនត្រូវចោទ**
អៀង សារី

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 04 / AUG / 2008
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: C.A. FRY

**មេធាវីដើមបណ្តឹងរដ្ឋប្បវេណី**
ហុង គីមសួន
ឡោ ជុនធី
នី ចាន់ឌី
គង់ ពិសី
Silke Studzinsky
យុង ផានិត

**សហមេធាវីការពារក្តី**
អាង ឧត្តម
Michael G. KARNAVAS

PRE-TRIAL CHAMBER CHAMBRE PRELIMINAIRE E.C.C.C. C.E.T.C.

១. **អង្គបុរេជំនុំជម្រះ នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា** (**"អវតក"**) បានកត់សម្គាល់ឃើញមាន "បណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី ("ជនត្រូវចោទ") ប្រឆាំងនឹងសេចក្តីសម្រេចរបស់ ក.ស.ច.ស លើសំណើរបស់សហមេធាវីការពារក្តីសុំព័ត៌មានទាក់ទងនឹងភាពលំអៀងដែលឃើញច្បាស់ និង អត្ថិភាពដ៏មានសក្តានុពលនៃទំនាស់ផលប្រយោជន៍នៃមន្ត្រីផ្នែកច្បាប់របស់ ក.ស.ច.ស លោក ដេវិដ បយលី ("បណ្តឹងឧទ្ធរណ៍") ចុះថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០០៨។

២. អនុលោមតាមវិធាន ៧៧(៣) នៃវិធានផ្ទៃក្នុង អង្គបុរេជំនុំជម្រះត្រូវកំណត់ថ្ងៃសវនាការ បន្ទាប់ពីទទួលបានបណ្តឹឧទ្ធរណ៍ ឬពាក្យសុំ ។[1]

៣. ប៉ុន្តែ អង្គបុរេជំនុំជម្រះសង្កេតឃើញថា នៅក្នុងចម្លើយតបចំពោះសារណារបស់លោក អៀង សារី អំពីទំនាស់ផលប្រយោជន៍របស់មន្ត្រីស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេត ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៨ សហព្រះរាជអាជ្ញាបានលើកឡើងថា "វាជាករណីសមស្របដែលបណ្តឹងឧទ្ធរណ៍នេះយកមកធ្វើការសម្រេច ដោយផ្អែកលើសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរណ៍ មិនចាំបាច់បើកសវនាការដេញដោលផ្ទាល់មាត់។"[2]

៤. នៅថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០០៨ សហមេធាវីការពារក្តីបានជូនដំណឹងដល់អង្គបុរេជំនុំជម្រះថា ខ្លួនបានយល់ស្របតាមការលើកឡើង ហើយបានស្នើអោយអង្គបុរេជំនុំជម្រះចេញសេចក្តីសម្រេចតាមវិធីនេះ។[3]

៥. បន្ទាប់ពីធ្វើការពិចារណាការយល់ឃើញរបស់ភាគីដែលបានលើកឡើងនៅក្នុងសេចក្តីសន្និដ្ឋានរបស់ពួកគេរួចមក អង្គបុរេជំនុំជម្រះយល់ឃើញថា បណ្តឹងឧទ្ធរណ៍នេះអាចយកមកធ្វើការសម្រេច ដោយផ្អែកលើតែសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សររបស់ភាគី។

---

[1] វិធានផ្ទៃក្នុងនៃ អ.វ.ត.ក (វិសោធនកម្មលើកទី១) ចុះថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ២០០៨។

[2] ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសារណារបស់ អៀង សារី ស្តីពីទំនាស់ផលប្រយោជន៍នៃអ្នកស៊ើបអង្កេតរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេត ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៨ A162/III/2 វាក្យខណ្ឌទី៤។

[3] ពាក្យសុំឱ្យអង្គបុរេជំនុំជម្រះធ្វើការសម្រេចលើបណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី ដោយផ្អែកលើសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរតែប៉ុណ្ណោះ ដែលបានធ្វើឡើងចំពោះសំណើសុំពន្យាររយៈពេលកំណត់ និងសេចក្តីសម្រេចរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេតស្តីពីសំណើរបស់សហមេធាវីការពារក្តីសុំព័ត៌មានទាក់ទងនឹងភាពលំអៀងដែលឃើញច្បាស់ និង អត្ថិភាពដ៏មានសក្តានុពលនៃទំនាស់ផលប្រយោជន៍នៃមន្ត្រីផ្នែកច្បាប់របស់ ក.ស.ច.ស លោក ដេវិដ បយលី ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០០៨ A162/III/3 វាក្យខណ្ឌទី១។

៦. អនុលោមតាមមាត្រា ៨(៤) នៃសេចក្តីណែនាំអនុវត្តនៃការដាក់ឯកសារចំពោះ អ.វ.ត.ក សំណើឆ្លើយតបចំពោះសារណានឹងត្រូវអនុញ្ញាត ក្នុងករណីដែលមិនមានអំណះអំណាងដេញដោលដោយផ្ទាល់មាត់។[4] ដូច្នេះ នៅក្នុងសេចក្តីសម្រេចរបស់ខ្លួនលើបណ្តឹងឧទ្ធរណ៍ អង្គបុរេជំនុំជម្រះនឹងយកសំណើឆ្លើយតបចំពោះសារណាតបរបស់ជនត្រូវចោទដែលបានដាក់នៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៨ មកធ្វើការពិចារណា។[5]

**ហេតុដូច្នេះអង្គបុរេជំនុំជម្រះសម្រេច:**

បណ្តឹងឧទ្ធរណ៍នឹងធ្វើការសម្រេច ដោយផ្អែកលើសេចក្តីសន្និដ្ឋានតបរបស់ភាគីតែប៉ុណ្ណោះ។

ភ្នំពេញ ថ្ងៃទី០៤ ខែសីហា ឆ្នាំ២០០៨

**ប្រធានអង្គបុរេជំនុំជម្រះ**

PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. * C.E.T.C.

ប្រាក់ គឹមសាន

[4] សេចក្តីណែនាំអនុវត្ត អ.វ.ត.ក/០១/២០០៧/វិសោធនកម្មលើកទី២។

[5] សេចក្តីសន្និដ្ឋានតបរបស់លោក អៀង សារី ចំពោះសេចក្តីសន្និដ្ឋានតបរបស់សហព្រះរាជអាជ្ញាចំពោះបណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី ដែលបានប្តឹងប្រឆាំងនឹងសេចក្តីសម្រេចរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេតស្តីពីសំណើរបស់សហមេធាវីការពារក្តីសុំព័ត៌មានទាក់ទងនឹងភាពលំអៀងដែលឃើញច្បាស់ និង អត្ថិភាពដ៏មានសក្តានុពលនៃទំនាស់ផលប្រយោជន៍នៃមន្ត្រីផ្នែកច្បាប់របស់ ក.ស.ច.ស លោក ដេវិដ បយលី ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៨ A162/III/៤។